# ៦– ទីស្តីការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

## ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ១១៨ ប្រក.វវស.ម**

**ស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យប្រធានបទសម្រាប់**
**ប្រឡងបញ្ចប់បរិញ្ញាជំនាន់ទី ២ ឆ្នាំ សិក្សា ១៩៩៥–៩៦**
**របស់មហាវិទ្យាល័យស្ថាបត្យកម្ម និង នគរោបនីយវិទ្យា**
**នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ**

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

–បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១.១១.៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

–តាមសំណើរបស់សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

**សំរេច**

**ប្រការ ១** : បង្កើតគណៈកម្មការមួយ ដើម្បីត្រួតពិនិត្យប្រធានបទសម្រាប់ការប្រឡងបញ្ចប់បរិញ្ញាជំនាន់ ទី២ នៃមហាវិទ្យាល័យស្ថាបត្យកម្ម និងនគរោបនីយវិទ្យានៃសាកលវិទ្យាល័យភូមិន្ទវិចិត្រ សិល្បៈ ។

**ប្រការ ២** : គណៈកម្មការរួមមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១–លោក **ឌុយ គឿន** | ប្រធាន |
| ២–លោក **គឿង សុគ័ណ្ណ** | អនុប្រធានអចិន្ត្រៃយ៍ |
| ៣–អ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ កុលធ័គ** | សមាជិក |
| ៤–លោកសាស្ត្រាចារ្យ **សារ៉ាតូ** | សមាជិក |

៥-លោកសាស្ត្រាចារ្យ**ឆិន ឆិនណា** សមាជិក

**ប្រការ ៣** : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានបច្ចេកទេស សកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ព្រមទាំងសាមីខ្លួនមានភារកិច្ចអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**នុត ណារ៉ាំង**

* * *

## ៧-ទីស្តីការក្រសួងធម្មការ និង សាសនា

## សេចក្តីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ១៩៨៦

**សេចក្តីសំរេចលេខ ១៣៣/៨៦ កធស**

**ស្តីពីការអនុញ្ញាតអោយសាងសង់វិហារ**

**ឥស្លាមភូមិទ្រាទី ២ ឃុំទ្រា ស្រុកក្រូចឆ្មារ**

**ខេត្តកំពង់ចាម**

រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១.១១.៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនាដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស.រកម ០១៩៦-១៩ ចុះថ្ងៃទី២៤.០១.៩៦
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២